# វេទិកាវៀនសូត្រស្តីពីការគ្រប់គ្រងធនធានមនុស្សលើកទី ៤៣

## ប្រធានបទ៖

## ការប្រើប្រាស់ប្រព័ន្ធទិន្នន័យរួម របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ សម្រាប់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល

*ថ្ងៃទី ១ ខែ តុលា ឆ្នាំ ២០២១*
*ម៉ោង ៨:៣០ ដល់ ១២:០០ ថ្ងៃត្រង់*
*តាមរយៈប្រព័ន្ធអនឡាញ **ZOOM***

## I. សេចក្តីផ្តើម

ក្នុងកំឡុងពេលវិបត្តិកូវីតសកល ប្រជាជនទូទាំងសកលលោក រួមទាំងប្រទេសកម្ពុជាផងដែរបាននឹងកំពុងប្រយុទ្ធប្រឆាំងយ៉ាងសកម្មបំផុត។ គ្រប់គ្នាបានប្រើប្រាស់គ្រប់យន្តការសុវត្ថិភាព តាមរយៈការរក្សាគំលាត ពាក់ម៉ាស់ និងលាងដៃ។ រាជរដ្ឋាភិបាលកម្ពុជាតាមរយៈក្រសួងសុខាភិបាលនិងក្រសួងនានា ក៏បាននិងកំពុងធ្វើការយ៉ាងមមាញឹកទប់ទល់តាមរយៈការប្រើប្រាស់វិធានការណ៏ច្បាប់ បទបញ្ញាតិ និងការជួយសង្គ្រោះផ្សេងៗ ព្រមទាំងការរៀបចំប្រើប្រាស់ប្រពន្ធ័ទំនើបកម្ម ពិសេសប្រពន្ធ័សេវាស្វ័យប្រវត្តិកម្ម ។ សមាគម និងអង្គការមិនមែនរដ្ឋាភិបាលក៏បានចូលរួមទប់ស្កាត់ការរីករាលដាលនៃជំងឺរាតត្បាតសកល កូវីត១៩នេះយ៉ាងសកម្មផងដែរ តាមរយៈការអនុវត្តរាល់គោលការណ៍ដែលបានដាក់ចេញដោយក្រសួងពាក់ព័ន្ធ។

ដើម្បីឆ្លើយតបនឹងតម្រូវការសមាជិករបស់ខ្លួនផង និងចូលរួមចំណែកទប់ស្កាត់នៃការរីករាលដាលនៃជម្ងឺកូវីដ ១៩ តាមរយៈការអនុវត្តវិធានការណ៍ និងសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា ព្រមទាំងក្រសួងពាក់ព័ន្ធនានា **អង្គការ គ.ស.ក** នឹងរៀបចំវេទិកាវៀនសូត្រស្តីពីការគ្រប់គ្រងធនធានមនុស្សលើកទី៤៣ តាមរយៈប្រព័ន្ធអនឡាញ(ZOOM) ក្រោមប្រធានបទ **ការប្រើប្រាស់ប្រព័ន្ធទិន្នន័យរួម របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ សម្រាប់សមាគមនិងអង្គការមិនមែនរដ្ឋាភិបាល** Online registration ។

ត្រឹមខែមិថុនា ឆ្នាំ២០២១ គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា ហៅកាត់ថា (គសក) មានសមាជិកសរុបទាំងអស់ចំនួន ១៧៨ស្ថាប័ន ទាំងអង្គការក្នុងស្រុក និងអង្គការបរទេស ដែលធ្វើការលើវិស័យអភិវឌ្ឍន៍ផ្សេងៗគ្នា និងជាវេទិកាសមាជិកមួយធំជាងគេបំផុតសម្រាប់អង្គការសង្គមស៊ីវិលនៅក្នុងប្រទេសកម្ពុជា។

## II. គោលបំណងនៃវេទិការៀនសូត្រ

១. ទទួលបានព័ត៌មានបន្ថែមពីសារៈសំខាន់ និងអត្ថប្រយោជន៍នៃការប្រើប្រាស់ ការឈ្មោះប្រើប្រាស់ប្រព័ន្ធទិន្នន័យរួម (សេវាស្វ័យប្រវត្តិកម្ម Online registration)

២. បានយល់ដឹងស្តីពីបច្ចេកទេសប្រើប្រាស់ប្រព័ន្ធទិន្នន័យរួម (សេវាស្វ័យប្រវត្តិកម្ម Online registration) វេបសាយនិងការចុះឈ្មោះ

៣. ចែកចាយបទពិសោធន៍ពីមន្ត្រីជំនាញ ក្នុងវគ្គសំនួរ ចំលើយ

## III. អ្នកចូលរួមគោលដៅ

វេទិកានេះ ត្រូវបានរៀបចំឡើងសម្រាប់ **អ្នកជំនាញវិជ្ជាជីវៈ និងអ្នកប្រតិបត្តិការគ្រប់គ្រងធនធានមនុស្ស** ដែលអញ្ជើញមកពី **សមាគម និងអង្គការមិនមែនរដ្ឋាភិបាល** ក្នុងប្រទេសកម្ពុជា។

## IV. របៀបចុះឈ្មោះ

អ្នកចូលរួមទាំងអស់តម្រូវឲ្យចុះឈ្មោះជាមុន ដើម្បីទទួលបានតំណរថ្មី (New Link) ពីក្រុមការងារ អង្គការ គសក ក្នុងការចូលរួមវេទិការៀនសូត្រនេះ។ តំណរនឹងផ្ញើជូនអ្នកដែលបានចុះឈ្មោះ និងបំពេញតាមលក្ខខណ្ឌ**មួយថ្ងៃមុនវេទិកា**រៀនសូត្រចាប់ផ្តើម។

## V. របៀបវារៈ

| ម៉ោង | មាតិកា | អ្នកសម្របសម្រួល |
|---|---|---|
| ០៨:០០-០៨:៣០ | ការចុះឈ្មោះអ្នកចូលរួម | • ក្រុមការងារ គសក |
| ០៨:៣០-០៨:៤០ | - ការណែនាំពីរបៀបប្រើ ZOOM និង បទបញ្ជាផ្ទៃក្នុងវគ្គ<br>- គោលបំណងវេទិការៀនសូត្រ | **លោក លឹម ឌីណា**<br>អ្នកឯកទេសផ្នែកកៀរគរធនធាន អង្គការ គ.ស.ក |
| ០៨:៤០-០៨:៥០ | កិច្ចស្វាគមន៍ និងបើកកម្មវិធី | **អ្នកស្រី ស៊ិន ពុទ្ធារី**<br>នាយិកាប្រតិបត្តិ អង្គការ គ.ស.ក |
| ០៨:៥០-០៩:០០ | - **វីឌីអូ ពីរបៀបចុះឈ្មោះប្រើប្រាស់ប្រព័ន្ធទិន្នន័យរួម (សេវាស្វ័យប្រវត្តិកម្ម Online registration)** | **លោក សេង សារ៉ុផ**<br>តំណាងសមាជិកក្រុមការងារ (HR Working Group) |

DRAFT

| | | |
|---|---|---|
| ០៩:០០-១០:០០ | - **បទបង្ហាញពីរបៀបចុះឈ្មោះប្រើប្រាស់ប្រព័ន្ធទិន្នន័យរួម (សេវាស្វ័យប្រវត្តិកម្ម Online registration)** | តំណាង មន្ត្រីពីក្រសួង |
| ១០:០០-១០:១០ | សំរាក | |
| ១០:១០-១១:៤៥ | - **សំនួរ ចំលើយ** | តំណាងសមាជិកក្រុមការងារ (HR Working Group) |
| ១១:៤៥-១២:០០ | បិទកម្មវិធី | តំណាងសមាជិកក្រុមការងារ (HR Working Group) |

***<u>កំណត់សម្គាល់:</u>*** *អង្គការ គសក សូមរក្សាសិទ្ធិផ្លាស់ប្តូរ ឬ កែប្រែរបៀបវារៈនៃកម្មវិធីក្នុងករណីចាំបាច់។*

DRAFT